# ឈ្វេងយល់ខ្លះៗអំពីរាជធានីសម័យអង្គរ (ភាគ២)
# រាជធានីយសោធរបុរៈក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១
# (៨៨៩គ.សដល់៩១០គ.ស)

ក្នុងអត្ថបទទី៣ ខ្ញុំបានលើកមកបង្ហាញអំពីរាជធានីហរិហរាល័យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៣ និងព្រះបាទឥន្ទ្រវរ្ម័នទី១ ដែលរាជនធានីនោះមានការប្រែប្រួលច្រើន ពោលគឺមានសំណង់ធំៗសំខាន់មួយចំនួនដែលត្រូវបានកសាងឡើងដោយព្រះបាទឥន្ទ្រវរ្ម័នទី១ សម្រាប់បុព្វការីជន ទេពនិងរាជ្យ និងសាធារណៈ។ ការសន្និដ្ឋានដំបូង ព្រះរាជវាំងអាចជាប្រាសាទព្រៃមន្ទីរ ហើយក្រោយមក អាចស្ថិតក្នុងបរិវេណនៃកស្សិណរបស់ប្រាសាទព្រះគោ ក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី១។

ព្រះបាទយសោវរ្ម័នទី១ ជាព្រះរាជបុត្ររបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ ហើយទ្រង់បានឡើងសោយរាជ្យបន្តពីព្រះបិតាក្នុងឆ្នាំ៨៨៩គ.ស។ ពិធីឡើងគ្រងរាជ្យរបស់ព្រះអង្គអាចប្រព្រឹត្តិទៅនៅក្នុងតំបន់ហរិហរាល័យនៅឡើយ។ ក្រោយឡើងសោយរាជ្យ ព្រះអង្គបានសម្រេចព្រះទ័យផ្លាស់ប្តូររាជធានីថ្មី ដោយបានចាកចោលរាជធានី នគរហរិហរាល័យ (តែមិនទាំងស្រុង) ទៅតំបន់ខាងជើងឈៀងខាងលិច ចម្ងាយប្រហែល១៥គ.ម (រូបលេខ១) នោះគឺតំបន់អង្គរសព្វថ្ងៃ។ គេមិនដឹងអំពីមូលហេតុដែលនាំឱ្យព្រះអង្គសម្រេចព្រះទ័យផ្លាស់ប្តូររាជធានីនោះទេ។ លោក Claude Jacques[១] បានលើកហេតុផលដែលផ្លាស់ប្តូរនេះគឺដោយសារជម្ងោះ។

## ទីក្រុងថ្មី និងហេដ្ឋារចនាសម្ព័ន្ធ

ព្រះអង្គបានជ្រើសរើសយកកូនភ្នំធម្មជាតិមួយ កម្ពស់ប្រហែល៦៥ម៉ែត្រ[២] ធ្វើជាផ្ចិតកណ្តាលនៃរាជធានី គឺភ្នំបាខែងសព្វថ្ងៃ ដែលឈ្មោះដើមហៅថា **វ្នំកន្តាល។**[៣] ព្រះបាទ

[១] Claude Jacques 2000:54, *Angkor-Cité Khmèr*, River Book, Bangkor.

[២] Lawrence Palmer Briggs 1951:110

[៣] សុខ កែវ សុវណ្ណារ៉ា ២០២១

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

KHMER CIVILIZATION

យសោវរ្ម័នបានប្រសិទ្ធិនាមភ្នំនោះថា **យសោធរបវ៌ត**[៤] (K.444) ឬ**យសោធរគីរី**[៥] (K.382) មានន័យថា ភ្នំរបស់ព្រះបាទយសោវរ្ម័ន។ ព្រះអង្គបានឱ្យគេស្ថាបនាប្រាសាទមួយធ្វើអំពីថ្មភក់ និងថ្មបាក្រៀម (រូបលេខ២) មានកំពូលចំនួន១០៩ (១០៨+១=១០៩) ជាប្រាសាទ (រូបលេខ៣) តំណាងឱ្យរាជ្យ ដោយមានតំកល់បដិមាសិវលិង្គធំមួយនៅប្រាង្គកណ្តាល ហើយជានិមិត្តរូបតំណាងឱ្យព្រះអង្គផ្ទាល់ មានឈ្មោះហៅថា **យសោធរេស្វរៈ**។ សិវលិង្គរបស់ប្រាង្គកណ្តាលនេះត្រូវបានគេរុះរើយកចេញបាត់ គឺប្រហែលក្នុងសម័យក្រោយអង្គរ ខណៈពេលដែលគេបានកែប្រែប្រាង្គកណ្តាលនេះទៅជាបដិមាព្រះពុទ្ធទ្រង់ភ្នែនដ៏ធំមួយ ហើយបដិមាសិវលិង្គត្រូវបានគេយកទៅទម្លាក់ចោលនៅជម្រាលជើងភ្នំ ក្រោយមកក្រុមការងារជួសជុលប្រាសាទភ្នំបាខែងបានរកឃើញវិញ(រូបលេខ៤)។[៦] គេបានស្ថាបនាជណ្តើរធ្វើអំពីថ្មបាយក្រៀមនៅគ្រប់ទិស និងមានកំពែងមួយជាន់ព័ទ្ធជុំវិញជើងភ្នំកន្តាល និងមានប្រាង្គរណបតូចមួយចំនួនធ្វើអំពីឥដ្ឋនិងថ្មភក់ (រូបលេខ៥)។ តាមស្នាកស្នាមដែលនៅសល់ផ្នែកខ្លះនៃកំពែងខាងក្រៅធ្វើអំពីដី គេបានសន្និដ្ឋានថា ព្រះបាទយសោវរ្ម័នទី១បានឱ្យគេស្ថាបនាទំនប់ដីដ៏ធំជាព្រំខណ្ឌនៃទីក្រុងរបស់ព្រះអង្គ ដែលមានបរិមាត្រប្រហែល ១៦គ.ម គឺប្រហែល៤គ.ម បួនជ្រុង (រូបលេខ៦-៧)។ តាមសិលាចារិក ស្តុកកក់ធំ K.235 បង្ហាញថា ព្រះបាទយសោវរ្ម័នទី១[៧]បានឱ្យគេស្ថាបនាទីក្រុងថ្មី ហើយព្រះអង្គបានប្រសិទ្ធិនាមទីក្រុងថ្មីរបស់ព្រះអង្គហៅថា **នគរ គ្រីយសោធរបុរៈ**។ នៅខាងក្រៅរាជធានី ព្រះអង្គបានឱ្យគេស្ថាបនាប្រាសាទធំៗ២ទៀតនៅលើភ្នំធម្មជាតិ គឺប្រាសាទភ្នំក្រោម (រូបលេខ៨) និងប្រាសាទភ្នំបូក (រូបលេខ៩) ដែលឧទ្ទិសដល់ទេពទាំង៣ក្នុងហិណ្ឌូសាសនា គឺត្រិមូរតិមានព្រះសិវៈ ព្រះវិស្ណុ និងព្រះព្រហ្ម។ នៅភាគឥសាន្តទីក្រុងយសោធរបុរៈ ព្រះអង្គបានឱ្យគេសាងសង់បារាយណ៍ទឹកយ៉ាងធំមួយ ឈ្មោះហៅថា **យសោធរតដាក**[៨] មានបណ្តោយពី

[៤] Cœdès, G. 1942:63

[៥] Cœdès, G. 1953:271

[៦] សុខ កែវ សុវណ្ណារ៉ា, ២០២១

[៧] Chhany Sak. Humphry 2005:117

[៨] Cœdès, G. 1952:182

កើតទៅលិចប្រហែល៧គ.ម និងទទឹងពីជើងទៅត្បូងប្រហែល១.៨គ.ម (រូបលេខ១០[៩])។ ព្រះអង្គបានស្ថាបនាផ្លូវមួយដើម្បីភ្ជាប់ពីរាជធានីថ្មី មករាជធានីហរិហរាល័យ គឺពីខាងកើតភ្នំបាខែងមកជ្រុងពាយ័ព្យនៃបារាយណ៍ **ឥន្ទ្រតដក**។ ព្រះអង្គអាចស្ថាបនាផ្លូវផ្សេងៗទៀតទៅតាមទិសសំខាន់ៗ។ ស្នាកស្នាមសំខាន់១ គឺជាប្រព័ន្ធព្រែកជីកដែលភ្ជាប់ពីទំនប់ខាងត្បូងនៃកំពែងទីក្រុង ឆ្ពោះទៅតំបន់ភ្នំក្រោម ដែលអាចជាផ្លូវទឹកប្រើប្រាស់ជាប្រព័ន្ធដឹកជញ្ជូនថ្មមកស្ថាបនាសំណង់នានាក្នុងទីក្រុង (រូបលេខ១១)។ ក្រៅពីនេះ ព្រះអង្គបានស្ថាបនាអាស្រមបែបពុទ្ធសាសនាជាច្រើននៅតំបន់អង្គរ ពិសេសតំបន់បារាយណ៍យសោតដក និងទូទាំងអាណាចក្រព្រះអង្គផងដែរ។[១០]

**តើរាជវាំងរបស់ព្រះអង្គស្ថិតនៅកន្លែងណា?**

ជាការពិតណាស់ ការសិក្សាស្រាវជ្រាវលើទីតាំងរាជវាំងរបស់ក្រុងយសោធរបុរៈនៅមិនទាន់មានភស្តុតាងជាក់លាក់ដើម្បីបកស្រាយទេ។ អ្នកស្រាវជ្រាវភាគច្រើនគិតថា វាស្ថិតនៅក្នុងតំបន់ខាងជើង (អាចក្នុងតំបន់រាជវាំងអង្គរធំបច្ចុប្បន្ន)។

ព្រះបាទយសោវរ្ម័នទី១ បានគង់នៅក្នុងក្រុងនោះ ហើយបានសុគតនៅទីនោះដែរ។ ព្រះរាជបុត្រ២អង្គរបស់ទ្រង់បានឡើងសោយរាជ្យជាបន្តបន្ទាប់ ប៉ុន្តែដោយសារមានជម្លោះរាជបល្ល័ង្ក ចុងក្រោយព្រះបាទជ័យវរ្ម័នទី៤ធ្វើគត់បុត្រាទាំង២ និងប្រកាសឡើងសោយរាជ្យក្នុងឆ្នាំ ៩២៨គ.ស និងបានផ្លាស់ប្តូររាជធានីពីយសោធរបុរៈទៅកោះកេរ្ត៍។

អរិយធម៌ខ្មែរ KHMER CIVILIZATION

៩ Claude Jacques and Michael Freeman 1997:75

១០ Cœdès, G. 1942:231-233. *Inscription du Cambodge*, Volume II, Hanoi.




រូបលេខ១៖ ការចាកចេញពីមហេន្ទ្របរ៌តមកហរិហរាល័យ និងការផ្លាស់ពីហរិហរាល័យទៅយសោធរបុរៈ



រូបលេខ២៖ ប្រាសាទភ្នំបាខែង (រូបថត លោក ខៀវ ច័ន្ទ)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ៣៖ ប្លង់ប្រាសាទភ្នំបាខែង បង្ហាញពីប្រាង្គចំនួន១០៩



រូបលេខ៤៖ សិវលិង្គដែលគេរើចេញពីប្រាង្គកណ្តាល (រូបថត លោក ជាសារិទ្ធ)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៥៖ ប្រាង្គតូចៗធ្វើអំពីឥដ្ឋនិងថ្មភក់នៅជុំវិញជើងភ្នំបាខែង (ប្រាង្គអាគ្នេយ៍)



រូបលេខ៦៖ ទំនប់ដីរបស់កំពែងខាងក្រៅក្រុង (ទំនប់ខាងលិច)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ៧៖ រាជធានីយសោធរបុរៈក្នុងរាជព្រះបាទយសោវរ្ម័នទី១ (Briggs)



រូបលេខ៨៖ ប្រាសាទភ្នំក្រោម



រូបលេខ៩៖ ប្រាសាទភ្នំបូក




រូបលេខ១០៖ រាជធានីយសោធរបុរៈក្នុងរាជព្រះបាទយសោវរ្ម័នទី១ (Jacques)




រូបលេខ១១៖ រចនាសម្ព័ន្ធរាជធានីយសោធរបុរៈក្នុងរាជព្រះបាទយសោវរ្ម័នទី១

## ឯកសារយោង


សុខ កែវ សុវណ្ណារ៉ា (២០២១), *ឈ្មោះដើមរបស់ភ្នំបូក*, ក្នុង , ភ្នំពេញ

សុខ កែវ សុវណ្ណារ៉ា, ២០២១, *ពិធីកម្រតេងជគតតរាជ*, ក្នុង AMS, ភ្នំពេញ។

Chhany Sak. Humphry, (2005), *The Sdok Kak Thom Inscription*, Buddhist Institute.

Claude Jacques and Michael Freeman, (1997), *Angkor- Cities and Temples*, River Book, Bangkok.

Claude Jacques (2000), *Angkor-Cité Khmèr*, River Book, Bangkor.

Cœdès, G. (1942), *Inscription du Cambodge*, Volume II, Hanoi.

Cœdès, G. (1952), *Inscription du Cambodge*, Volume IV, Paris.

Cœdès, G. (1953), *Inscription du Cambodge*, Volume III, Paris.

Lawrence Palmer Briggs, (1951), *The Ancient Khmer Empire*, Transactions of the American Philosophical Society, 4 (1).